# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៧ សសរ

## សេចក្តីសំរេច

## ស្តីពីការបង្កើតគណៈកម្មការ សំរាប់ដោះស្រាយ បញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការ សំរាប់ដោះស្រាយកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលមានសមាសភាពដូចខាងក្រោម :

១- ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន

២- ឯកឧត្តម **ញ៉ែប ប៊ុន ជិន** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អនុប្រធាន

៣- ឯកឧត្តម **ហុក ឡុងឌី** អគ្គស្នងការ នគរបាលជាតិ អនុប្រធាន

៤- ឯកឧត្តមអភិបាលក្រុងភ្នំពេញ អនុប្រធាន

| | | | |
|---|---|---|---|
| ៥- | ឯកឧត្តម **ម៉ុក ថន** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៦- | ឯកឧត្តម **មិន ឃិន** | រដ្ឋលេខាធិការក្រសួងធម្មការ និង កិច្ចការសាសនា | សមាជិក |
| ៧- | ឯកឧត្តម **មល់ រឿម** | ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៨- | ឯកឧត្តម **ខួត រ៉ាន់នី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល | សមាជិក |
| ៩- | ឯកឧត្តម **គឹម ស៊ីថន** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- | ឯកឧត្តម **ប៊ុន សម** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- | ឯកឧត្តម **ស្វាយ ស៊ីថា** | អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១២- | ឯកឧត្តម **អ៊ឹ មាន** | អនុរដ្ឋលេខាធិការក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៣- | ឯកឧត្តម **សៅ សុខា** | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៤- | ឯកឧត្តម អភិបាលខេត្តរងខេត្តកណ្តាល | | សមាជិក |
| ១៥- | ឯកឧត្តម **ជុំ ហាក់** | មេបញ្ជាការរងកងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |

**ប្រការ ២:** គណៈកម្មការនេះ មានភារកិច្ច :

- តាមដាន ទប់ស្កាត់ និង លើកវិធានការដោះស្រាយអោយមានប្រសិទ្ធភាព នូវរាល់បញ្ហាកូដកម្ម បាតុកម្ម ដែលកើតមានឡើងនៅតាមគ្រប់មុខសញ្ញា ។
- ធ្វើរបាយការណ៍ អំពីវិធានការដំណោះស្រាយ និង លទ្ធផលនៃការងារខាងលើ ជូនរាជរដ្ឋាភិបាល ។

**ប្រការ ៣:** គណៈកម្មការនេះ ត្រូវបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចាត់ចែងការងារប្រចាំថ្ងៃ ។

**ប្រការ ៤:** សមាជិកនៃគណៈកម្មការទាំងអស់ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ឯកឧត្តមប្រធាន។ គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សំរាប់សំរួលការងារ។

**ប្រការ ៥:** ថវិកាចំណាយប្រើប្រាស់របស់គណៈកម្មការនេះ ត្រូវបញ្ចូលបន្ថែម ក្នុងខ្ទង់ថវិការបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

**ប្រការ ៦:** បទបញ្ញត្តិទាំងឡាយណា ផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហា… រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និង បណ្ដុះបណ្ដាលវិ… ជីវៈ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងឧស្ស… ហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០០…

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ១
- ឯកសារ-កាលប្បវត្តិ